# ផ្នែកទី II ( ii )

# ផ្លាកសញ្ញាបណ្តោះអាសន្ន

# Temporary Signs

ផ្លាកសញ្ញាបណ្តោះអាសន្ន មានទ្រង់ទ្រាយនិងពណ៌ខុសៗគ្នា ។ ខ្លះរាងជាការេដែលមាន អង្កត់ទ្រូងមួយជាខ្សែឈរ ខ្លះរាងជាចតុកោណកែង ខ្លះរាងជាសាជី ខ្លះទៀតជាទង់ក្រណាត់ ។ល។

ផ្លាកសញ្ញាប្រភេទនេះជាទូទៅច្រើនប្រើ នៅពេលមានការដ្ឋានតាមផ្លូវថ្នល់ សំរាប់ការពារគ្រោះថ្នាក់ដល់កម្មករដែលកំពុងបំពេញភារកិច្ចនៅការដ្ឋាន ក៏ដូចជាអ្នកធ្វើចរាចរតាមផ្លូវដែរ ។ អ្នកបើកបរ ត្រូវតែបង្កើនការប្រុងប្រយត្ន័ អនុវត្តតាមអត្ថន័យរបស់ផ្លាកសញ្ញា ឬ តាមបញ្ជានៃអ្នកទទួលខុសត្រូវនៅកន្លែងនោះ ។



**មានការដ្ឋាន**

ROAD WORKS AHEAD

**លេខកូដ : PW03-W2-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ មានការដ្ឋាន នៅខាងមុខ ។

---



**ការដ្ឋាន**

ROAD WORKS

**លេខកូដ : PW03-W2-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ មានការដ្ឋាន ចាប់ផ្ដើមពីផ្លាកសញ្ញានេះទៅ ។

---



**ផ្លូវមានថ្មខ្ចាត**

LOOSE STONES

**លេខកូដ : PW03-W2-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ មានដុំថ្មក្រាលលើទ្រូងផ្លូវ ចាប់ពីផ្លាកសញ្ញានេះទៅ ។

---




**ចប់ ការដ្ឋាន**

END ROAD WORKS

**លេខកូដ : PW03-W2-04**

**ខ្លឹមសារ** : សញ្ញានេះប្រើសំរាប់អោយដំណឹងដល់អ្នកបើកបរ ពីចុងបញ្ចប់ នៃការដ្ឋាន ។




**ផ្លូវវាងទៅខាងស្តាំ**

DETOUR TO THE RIGHT

**លេខកូដ : PW03-W2-05**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញអ្នកបើកបរ អោយវាង តាមសញ្ញាព្រួញ ទៅស្តាំ ។

---




**ផ្លូវវាងទៅខាងឆ្វេង**

DETOUR TO THE LEFT

**លេខកូដ : PW03-W2-06**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញអ្នកបើកបរ អោយវាង តាមសញ្ញាព្រួញ ទៅឆ្វេង ។

---



**បង្គោលរាងសាជី**

TRAFFIC CONE

**លេខកូដ : PW03-W2-07**

**ខ្លឹមសារ :** បង្គោលសាជី ប្រើសំរាប់ ធ្វើជារនាំងការពារ បរិវេណ ការដ្ឋាន ឬ កន្លែងផ្សេងៗ ដែលចាំបាច់ ។

---



**សញ្ញាព្រួញបង្វែរទិស**

DIRECTION TO BE FOLLOWED

**លេខកូដ : PW03-W2-08**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្តូរទិស ទៅតាម មុខព្រួញ នៃផ្លាកសញ្ញា ។




## សញ្ញាឈប់

STOP SIGN

**លេខកូដ : PW03-W2-09**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ឈប់នៅពីមុខ ផ្លាកសញ្ញា ដែលកាន់ដោយ ភ្នាក់ងារការដ្ឋាន ។

---



## សញ្ញាបើកផ្លូវ

GO SIGN

**លេខកូដ : PW03-W2-10**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ បន្តដំណើរ ។

---



រូប ក



រូប ខ

## ទង់ក្រហម

RED FLAG

**លេខកូដ : PW03-W2-11**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ឈប់នៅមុខ ភ្នាក់ងារការដ្ឋាន ដែលកាន់ទង់ក្រហមសន្ធឹងកាត់ទទឹងថ្នល់ ( រូប ក ) ។ អ្នកបើកបរ អាចបន្តដំណើរបាន លុះត្រាភ្នាក់ងារការដ្ឋាន ដាក់ទង់ក្រហមចុះ ហើយដៃឆ្វេងធ្វើសញ្ញាបញ្ជាអោយទៅ ( រូប ខ ) ។